ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៩៦/១៤-ភើមៀវ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេង ថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ភើមៀវ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវវែងស្រែង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៦០ ៨៧៥ /០៩៨ ៨៨៨ ៨១៤ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

- លោក តាយ រតនា រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពសម្ព័ន្ធយុវជនខ្មែរ**

- **សហព័ន្ធសហជីពកម្មករខ្មែរ**

អាសយដ្ឋាន ៖ ផ្លូវវែងស្រែង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៤៨៨ ០៧៧ / ០១២ ៩០៧ ៩០២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◈ Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលប្រចាំថ្ងៃ និងប្រាក់រង្វាន់ផ្សេងៗ ក្នុងរយៈពេលកម្មករធ្វើកូដកម្ម។ ដោយឡែកភាគីតំណាងក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទាររបស់កម្មករនិយោជិត ឱ្យរក្សាលុយថ្ងៃ និងលុយរង្វាន់ (លុយព្រីម) ក្នុងថ្ងៃកូដកម្មបានឡើយ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៤៣៧ កប/អក/វក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងជួបប្រជុំមុនសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ** ៖ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៤ (វេលាម៉ោង ១៦ និង ៣០ នាទី រសៀល)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងតាមទូរស័ព្ទរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ភើម្សៀវ (ប៉ាយ ម៉ី) ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារមួយចំនួនជូនកម្មករនិយោជិតឱ្យបានល្អប្រសើរ។ ក្រោយពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះដល់ទីតាំងក្រុមហ៊ុន ដើម្បីធ្វើការដោះស្រាយ និងផ្សះផ្សាវិវាទការងាររួមនេះបញ្ចប់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១៧ចំណុច (ចំណុចទាមទារទី១, ទី២, ទី៣, ទី៤, ទី៥, ទី៦, ទី៧, ទី៨, ទី៩, ទី១០, ទី១១, ទី១២, ទី១៣, ទី១៤, ទី១៥, ទី១៦, និងទី១៧) និងមិនសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ១៨ ចំណុច នៅពេលផ្សះផ្សាដល់ចំណុចទី១៨ ទាក់ទងនឹងការទាមទារមិនឱ្យដាច់ប្រាក់ឈ្នួលប្រចាំថ្ងៃ និងអត្ថប្រយោជន៍ផ្សេងៗក្នុងថ្ងៃកូដកម្ម ការពិភាក្សាគ្នាពុំអាចរកដំណោះស្រាយបាន ភាគីតាំងខ្លួនជាតំណាងកម្មករនិយោជិត និងអ្នកអមបានដើរចេញពីអង្គប្រជុំ ហើយក៏ពុំព្រមចុះហត្ថលេខា ឬក៏ផ្តិត

មេដៃលើកំណត់ហេតុផ្សះផ្សាឡើយ។ ចំណុចមិនសះជាចំនួន ០១ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ភើមៀវ លេខ ៤៣៧ ក.ប/អក/វក. ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានថា កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន ប៉ាយ ម៉ី ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ស្តីពីសំណើសុំក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ភើ មៀវ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី ដែលបាននាំគ្នាធ្វើកូដកម្មរបស់កម្មករនិយោជិតបានចាប់ផ្តើមពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ រហូតដល់ថ្ងៃនេះ ដែលធ្វើឱ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០២២/១៤ កបអ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ភើមៀវ (ប៉ាយ ម៉ី) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាល ត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ តទៅ តាមវេនរបស់ខ្លួន។ យ៉ាងណាមិញ ក្រោយការចេញសេចក្តីបញ្ជានេះ កូដករនៅតែបន្តធ្វើកូដកម្ម ដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរ ព័ត៌មានបន្ថែមនៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ១៦៖៣០ នាទី រសៀល។ ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែភាគីកម្មករនិយោជិតមិនមានវត្តមានចូលរួម តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញា កណ្តាលទេ។

មុនកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ នាវេលាម៉ោង ០៨៖០២ នាទីព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទពីលោក ប៉ាង ចន្ទី ជាប្រធានសហព័ន្ធសហជីពកម្មករខ្មែរ បានបញ្ជាក់ថា កូដកម្មនៅតែបន្ត ដោយមានកូដករប្រមាណជា ១០០ នាក់ ឈរនៅខាងមុខរោងចក្រ។ ភាគីនិយោជកលោក តាយ រតនា ជារដ្ឋបាលក្រុមហ៊ុន បានបញ្ជាក់នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា លេខ ០២២/១៤ កបអ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ និយោជកបានបិទសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅខាងមុខរោងចក្រ និងបានផ្សព្វផ្សាយតាមរយៈប្រធានក្រុម និងប្រធានផ្នែក នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤។ កូដករប្រមាណ ២៧០នាក់ ក្នុងចំណោមកូដករសរុបប្រមាណ ៣៦០ នាក់ បានចូលធ្វើការវិញ នៅព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ប៉ុន្តែលុះដល់ថ្ងៃត្រង់កម្មករនិយោជិតប្រមាណ ១០០ នាក់ បានត្រឡប់ចូលរួមកូដកម្មវិញ ។ ភាគីនិយោជកបានបញ្ជាក់បន្ថែមថា បច្ចុប្បន្ននេះ កូដកម្មនៅតែបន្ត ដោយមានកូដករសរុបប្រមាណ ៧០ នាក់ ក្នុងនោះកូដករប្រមាណពី ១០ ទៅ ២០ នាក់ បានរារាំងកម្មករនិយោជិតដទៃមិនឱ្យចូលក្នុងរោងចក្រ បើទោះបីជានិយោជកបានបើកទ្វារឱ្យកម្មករនិយោជិតចូលធ្វើការវិញក៏ដោយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- សំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ភើមៀរ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភើមៀរ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី លេខ ៤៣៧ ក.ប/អក/វក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ភើមៀរ (ខេមបូឌា) ហ្គាមេន ខូអិលធីឌី ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០២២/១៤ កបអ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៤៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៤៩៧ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់*

*ធូរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម*"។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វូ, លេខ ៣៥/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៨/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ១១៥/១៣-ពូ យៀន, និងលេខ ០១៥/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា)*)។

នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តី ជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

"*ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម*"។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ព្រែនឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និងសូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ដែលចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះ ចែងដូចខាងក្រោម ៖

"*ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ*"។

"*ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ*"។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ហ្វ្រង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិនរ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។

នៅក្នុងសំណុំរឿង០៦៦/១៤ - កាល់លីស្តូ អ៊ីភេរីល (ខេមបូឌា) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចចេញសេចក្តីបង្គាប់បញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយហេតុថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរព

តាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ វេលាម៉ោង ១៦៖៣០ នាទី រសៀល។ ភាគីនិយោជកមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែភាគីកម្មករនិយោជិតមិនមានវត្តមានចូលរួមតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

មុនកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ នាវេលាម៉ោង ០៨៖០២ នាទី ព្រឹក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទពីលោក ប៉ាង ចន្នី ជាប្រធានសហព័ន្ធសហជីពកម្មករខ្មែរ បានបញ្ជាក់ថា កូដកម្មនៅតែបន្ត ដោយមានកូដករប្រមាណជា ១០០ នាក់ ឈរនៅ ខាងមុខរោងចក្រ។ ភាគីនិយោជក លោក តាយ រតនា ជារដ្ឋបាលក្រុមហ៊ុន បានបញ្ជាក់នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា លេខ ០២២/១៤ កបអ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៤ និយោជកបានបិទសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅខាងមុខរោងចក្រ និងបានផ្សព្វផ្សាយតាមរយៈប្រធានក្រុម និងប្រធានផ្នែកនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤។ កូដករប្រមាណ ២៧០ នាក់ ក្នុងចំណោមកូដករសរុបប្រមាណ ៣៦០ នាក់ បានចូលធ្វើការវិញ នៅព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ប៉ុន្តែលុះដល់ថ្ងៃត្រង់កម្មករនិយោជិតប្រមាណ ១០០ នាក់ បានត្រឡប់ចូលរួមកូដកម្មវិញ ។ ភាគីនិយោជកបានបញ្ជាក់បន្ថែមថា បច្ចុប្បន្នកូដកម្មនៅតែបន្ត ដោយមានកូដករសរុបប្រមាណ ៧០ នាក់ ក្នុងនោះកូដករប្រមាណពី ១០ ទៅ ២០ នាក់ បានរាំងកម្មករនិយោជិតដទៃមិនឱ្យចូលក្នុងរោងចក្រ បើទោះបីជានិយោជកបានបើកទ្វារ ឱ្យកម្មករនិយោជិតចូលធ្វើការវិញក៏ដោយ ។

ក្នុងករណីនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានពីភាគីនិយោជកក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជាលេខ ០២២/១៤ កបអ. របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ មានភាពស៊ីសង្វាក់ទៅនឹងព័ត៌មាន ដែលបានផ្តល់ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈទូរស័ព្ទ ដោយភាគីកម្មករនិយោជិតនៅមុនកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នាវេលាម៉ោង ០៨៖០២ នាទី ព្រឹក ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

ជាសរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៩៦/១៤-ភើមៀវ (ប៉ាយ មុី) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **ឈឹម តិរម្យ**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **អាំង អេង ថុង**

ហត្ថលេខា ៖ ------------------------------------